# ការសម្ភាសរបស់អ៊ុំស្រីច្រឹក ភី

កះ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខះ អ្នកត្រូវគេសំភាសន៍ឈ្មោះ ច្រឹក ភី

កះ ជាដំបូងសូមជំរាបសួរជាអ៊ុំ!

ខះ ចាស!ជំរាបសួរចាស!

(ឆ្កែព្រូស ព្រុសៗៗ)

កះ
ចាសជំរាបសួរអ៊ុំថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងមកធ្វើការសំភាសន៍ដល់អ៊ុំផ្ទាល់ហើយចឹងថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងធ្វើការសំភាសន៍ដែលខ្ញុំបានធ្វើការងារស្មោគចិត្តពីខាងសាលានៅសហរដ្ឋអាមេរិកហើយខាងសាលាគឺគាត់មានគំរោង១ដើម្បីនឹងធ្វើការសំភាសន៍ដល់ប្រជាជនកម្ពុជាទាក់ទងទៅនឹងប្រវត្តិរបស់គាត់
បទពិសោធន៍ជីវិតរបស់គាត់ដែលគាត់បានធ្លាប់បានឆ្លងកាត់មកតាំងពីកាលមុននឹងរហូតមកដល់ពេលឥឡូវនឹងគាត់មានឆ្លងកាត់ជីវិត
ដល់អស្ចារ្យអ្វីគេខ្លះហើយតើដំណើរជីវិតរបស់គាត់មានដំណើររឿងកាលពីមុននឹងមកមានជួបនឹងបញ្ហាអ្វីគេខ្លះដែរចាសចឹងតាំងពីកាលតស៊ូរបស់គាត់នឹងបទពិសោធន៍របស់គាត់ដែលតាំងពីមុនមកណាអ៊ុំ!

ខះ ចាស!

កះ
ចាស!គំរោង១នឹងគេបានជួយក្នុងការសំភាសន៍ប្រជាជនកម្ពុជាហើយធ្វើការរក្សានូវប្រវត្តិរបស់គាត់ទុក កុំអោយវាបាត់ចឹងៗ
ហើយគេបានទុកសំរាប់កូនចៅជំនាន់ក្រោយមកទៀតនឹងគេបានចង់វាសំរាប់អោយទុកកូនចៅជំនាន់ក្រោយមកទៀតនឹងកុំអោយបាត់ដែរចឹងណាអ៊ុំ!
ជាពិសេសនឹងកូនចៅរបស់អ៊ុំស្រីផ្ទាល់ដែលគាត់បានចូលទៅស្តាប់សំលេងរបស់អ៊ុំ១នឹងដែល

វានៅក្នុងវេបសាយរបស់ខាងសាលាហើយចឹងគាត់អាចធ្វើការស្វែងរកឈ្មោះរបស់អ៊ុំហើយគាត់អាចនឹងបានឃើញរូបភាពរបស់អ៊ុំហើយគេនឹងអាចធ្វើការស្តាប់សំលេងរបស់អ៊ុំបាន។

ចាសចឹងថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងមកសំភាសន៍អ៊ុំផ្ទាល់ចឹងហើយអ៊ុំអនុញ្ញាតដើម្បីអោយខ្ញុំបានធ្វើការrecordសំលេងរបស់អ៊ុំនឹងបានធ្វើការសំភាសន៍ដល់អ៊ុំបានដែរឬទេអ៊ុំ។

ខ៖ ចាស!ចឹងអោយខ្ញុំឆ្លើយថាយ៉ាងម៉េចទៅ?

ក៖ ចាស!អ៊ុំបើសិនជាអ៊ុំបានអនុញ្ញាតដើម្បីនឹងអោយខ្ញុំធ្វើការសំភាសន៍១នឹងដល់អ៊ុំអ៊ុំអាចឆ្លើយថាបានតែបើសិនជាអត់ទេអ៊ុំអាចឆ្លើយថាអត់បានចឹងទៅ ចឹងអ៊ុំឆ្លើយថាអត់បានទេចឹងទៅ។

ខ៖ អូ!ចឹងការសំភាសន៍១នឹងបើថាបានចឹងគេអោយឆ្លើយថាបានចឹងហ៎?

ក៖ ចាស! ចឹងអ៊ុំអាចនឹងអនុញ្ញាតដើម្បីនឹងអោយខ្ញុំធ្វើការសំភាសន៍ដល់អ៊ុំស្រីដែលឬទេ?

ខ៖ ចាស!អនុញ្ញាតបានចាស។

ក៖ ចាស!អរគុណច្រើនអ៊ុំហើយថ្ងៃនេះគឺជាថ្ងៃទី១៦ខែ៦ឆ្នាំ២០១៨។ ចឹងជាដំបូងនៃការសំភាសន៍ខ្ញុំសូមសួរដល់អ៊ុំថាអ៊ុំមានឈ្មោះអ្វីដែរ?

ខ៖ ចាស!ខ្ញុំមានឈ្មោះថា ច្រឹក ភី។

ក៖ ចាស!ហើយចឹងអ៊ុំមានឈ្មោះហៅក្រៅដែរឬទេ?

ខ៖ អត់មានទេមានតែឈ្មោះនឹងតែម្តងឈ្មោះនឹងវាជាឈ្មោះពិត។

ក៖ ចាស!ហើយឈ្មោះនឹងនរណាគេដែលបានដាក់ឈ្មោះនឹងអោយដល់អ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំ។

ក៖ ឪពុករបស់អ៊ុំអូ ចឹងពេលដែលគាត់បានដាក់ឈ្មោះនឹងអោយដល់អ៊ុំគាត់មានបានប្រាប់អ៊ុំថាឈ្មោះនឹងរបស់អ៊ុំមានអត្ថន័យអ្វីដែរឬទេបានជាគាត់ធ្វើការដាក់ឈ្មោះនឹងអោយ?

ខ៖ អត់មានបានប្រាប់ខ្ញុំអីផង។

ក៖ ចាស!ហើយអ៊ុំហើយសព្វថ្ងៃនឹងអ៊ុំមានអាយុបានប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំសព្វថ្ងៃនឹងខ្ញុំមានអាយុបាន៦០ហើយ អូ៦១ឆ្នាំហើយ។

ក៖ អ៊ុំបានកើតនៅក្នុងថ្ងៃខែឆ្នាំណាដែលទៅអ៊ុំ?

ខ៖ អូ!ខ្ញុំមិនបានចាំអីសោះ។

ក៖ ចាស!

ខ៖ វាបានកន្លងទៅយូរហើយនឹងចឹងហើយវាបានភ្លេចផ្លាំងអស់ទៅហើយ។

ក៖ ហឺស!

ខ៖ ហឺ!

ក៖ ចុះអ៊ុំដូចជាថ្ងៃខែឆ្នាំកំណើតរបស់អ៊ុំដែលត្រូវជាមួយនឹងឆ្នាំខ្មែររបស់យើងដែលមានដូចជាឆ្នាំចន្ទ័គតិ និងឆ្នាំសុរិយៈគតិអីនោះអ៊ុំមានបាននៅចាំដែរឬទេ? តើអ៊ុំបានកើតនៅក្នុងឆ្នាំណាដែរ?

ខ៖ ហឺ!កាលនៅក្នុងជំនាន់នឹងណោះខ្ញុំវាបានភ្លេចបាត់ទៅហើយកាលនឹងទាល់តែទៅមើលនៅក្នុងអត្តសញ្ញាតប័ណ្ណនឹងនៅក្នុងសៀវភៅគ្រួសារ។

ក៖ ចាស!ចឹងអ៊ុំមានបាននៅមានអត្តសញ្ញាប័ណ្ណមកដែលឬទេ?

ខ៖ ហឺ!វាបានអស់អាលីងហើយក្មួយស្រីអើយវាមិនទៅបាននៅសល់អីនោះទេវាបានបាត់ទៅអស់ហើយនឹង។

ក៖ ចឹងកាលនឹងអ៊ុំបានបាត់មែនអ៊ុំ?

ខ៖ ចាស!

ក៖ ហឺស!ចឹងបានសោកស្តាយមែនទែនអ៊ុំ!!ចឹងអ៊ុំមានបានទៅធ្វើថ្មីដែរឬទេ?

ខ៖
ចាស!អត់ផងនឹងកាលនឹងគេមកធ្វើអត្តសញ្ញាប័ណ្ណនឹងគេអោយទៅថតរូបនឹងតែខ្ញុំវាមិនទាន់បានទៅថតអីណា។

ក៖ ចាស!ចឹងហើយចឹងអ៊ុំសព្វថ្ងៃនឹងអ៊ុំមានទីលំនៅនៅឯណាដែលទៅអ៊ុំ?

ខ៖ សព្វថ្ងៃនឹងខ្ញុំមានទីលំនៅនៅតែក្នុងកោះនឹង។

ក៖ អ៊ុំអាចធ្វើការបញ្ជាក់ទីតាំងនឹងខេត្តទីបានដែរឬទេ?

ខ៖ អត់ផង!!

ក៖ អត់ទេអ៊ុំអ៊ុំអាចធ្វើការបញ្ជាក់និងមានន័យថាអ៊ុំហ៊ីស អ៊ុំអាចប្រាប់បានថាអ៊ុំរស់នៅក្នុងភូមិអីហើយនៅក្នុងឃុំអីហើយស្រុកអីគេដែរ?

ខ៖ អូ!ចឹងហេស?

ក៖ ចាស!

ខ៖ ខ្ញុំមានទីលំនៅនឹងគឺនៅក្នុងភូមិក្បាលកោះនឹង។

ក៖ នៅក្នុងឃុំអីដែរទៅអ៊ុំ?

ខ៖ ឃុំនឹងឃុំកោះឧញ្ញាតីនឹង។

ក៖ ចាស!នៅក្នុងខេត្តកណ្តាល?

ខ៖ ចាស!នៅក្នុងខេត្តកណ្តាល។

ក៖ ចាស!ចុះកាលពីទីលំនៅកាលពីមុនមកនឹងឡើយនឹងអ៊ុំមានទីលំនៅនៅឯណាដែរ?

ខ៖ នៅនឹងតែម្តង!

ក៖ ហើយចឹងអ៊ុំអត់មានធ្វើការផ្លាសប្តូរផ្ទះអីនោះទេ?

ខ៖ ចាស!អត់មានបានផ្លាស់ប្តូរនោះទេគឺនឹងនៅនឹងតែម្តងមកនឹងចាសអត់មានប្តូរនោះទេ។

ក៖ ចាស!អ៊ុំហើយចុះកាលពីមុននឹងអ៊ុំមានបានធ្វើការរៀននឹងសិក្សាដល់កំរិតណាដែលអ៊ុំ?

ខ៖ រៀនឹងហោស?

ក៖ ចាស!!

ខ៖ រៀននឹងបានរៀនបានត្រឹមថ្នាក់ទី១០តាំងពីសង្គមមកនឹងវាមិនសូវបានជាស្ទាត់អីណាទេកាលនឹងវាបានម៉ាល្មមនឹង។

ក៖ ចាស!ចឹងកាលនឹងអ៊ុំបានរៀនត្រឹមថ្នាក់ទី១០នឹងបានច្រើនដែលតើអ៊ុំចឹងកាលនឹងអ៊ុំបានរៀនឹងនឹងអ៊ុំអាចចេះអាច ចេះសរសេរបានដែរទេ?

ខ៖ ចាសចេះ។

ក៖ ហើយចឹងកាលនឹងអ៊ុំចេះបានប៉ុន្មានភាសាដែរ?

ខ៖ អត់បានដឹងទេកាលនឹងអត់បានរៀននោះទេក្មួយអើយវាបានភ្លេចបាត់ទៅហើយនឹងព្រោះអីខួរក្បាលនឹងវាដូចជានេសហាហាហា កាលនឹងវាមិនបាននៅចាំនោះទេមកដល់សព្វថ្ងៃនោះហ។

ក៖ ចាស!ចឹងកាលនឹងអ៊ុំមានបានរៀនភាសាក្រៅទេកាលនិង?

ខ៖ អត់បានរៀនផងកាលនឹងអ៊ុំរៀនបានតែត្រឹមភាសាខ្មែររបស់យើងនឹងព្រោះអីកាលនៅក្នុងជំនាន់នឹងនោះវាមិនបានទៅរៀនអីនោះទេកាលនឹងមានបានតែរៀនត្រឹមភាសាខ្មែរនឹង។

ក៖ ចាស!ហើយកាលនឹងអ៊ុំបានរៀននៅក្នុងសាលាណាដែរ?

ខ៖ សាលារៀននឹងគឺនៅគ្នុងសាលាវត្តកោះយើងនឹងតែម្តងនៅក្នុងវត្តនឹង។

ក៖ អូ!ចឹងរៀននៅក្នុងវត្តជិតនេះតែម្តង?

ខ៖ ចាស!!

ក៖ អូ!ចឹងនៅជិតផ្ទះចឹងវារាងបានស្រួលហើយចឹង។ ហឺសៗៗ

ខ៖ ចាស!

ក៖ ចាស!ហើយចឹងកាលនឹងមូលហេតុអ្វីបានជាអ៊ុំបានរៀនត្រឹមថ្នាក់ទី១០នឹងចឹងកាលនឹង?

ខ៖
កាលនឹងវាដូចថាយើងនឹងវាអត់ដែលនឹងហើយកាលនឹងវាគ្មានបានគ្រួសារណាច្រើនអីកាលនឹងនោះមានតែ២ទៅ៣នាក់ម្ដាយនឹងកូននិង។

ក៖ ចាស!ចឹងអ៊ុំសព្វថ្ងៃនឹងអ៊ុំមានគ្រួសារហើយឬនៅ?

ខ៖ អត់ផងខ្ញុំអត់ផងខ្ញុំអត់មានគ្រួសារផង។តែខ្ញុំមានកូន១នាក់ហើយ។

ក៖ អូ! កូនអ៊ុំ ហើយចឹងកូនរបស់អ៊ុំគាត់មានឈ្មោះអីគេដែលអ៊ី?

ខ៖ កូនរបស់ខ្ញុំនឹងគាត់មានឈ្មោះថា សុធា។

ក៖ ហើយគាត់មានមុខរបរជាអ្វីដែលទៅអ៊ុំ?

ខ៖ គេមានមុខរបរនឹងជាអ្នកត្បាញក្រមានឹងសូត្រនឹងចឹង។

ក៖ ចាសអូ ! ចឹងគាត់មានទីលំនៅនឹងនៅជាមួយនឹងអ៊ុំរហូតមកដល់សព្វថ្ងៃនឹងទេតើអ៊ុំ?

ខ៖ ចាស!គាត់បាននៅជាមួយនឹងគ្នា។

ក៖ ចុះចំណែកឯស្វាមីរបស់អ៊ុំវិញនឹង?

ខ៖ ហឺ!គាត់នឹងបានស្លាប់តាំងពីកាលនៅក្នុងសម័យពពតឯនោះ។

ក៖ គាត់មានឈ្មោះអ្វីដែលទៅអ៊ុំ?

ខ៖ គាត់មានឈ្មោះថាក្រឿន។

ក៖អូ!ហើយចុះកាលនឹងយ៉ាងម៉េចបានជាគាត់ស្លាប់វិញកាលនឹងនោះ?ឬក៏នៅក្នុងសម័យអាពត។

ខ៖ កាលនៅជំនាន់នឹងវាមានជំងឺនឹងណាកាលជំនាន់នឹង។ គាត់បានឈឺទៅហើយពេលនឹងគាត់បានឈឺហើយពេទ្យគេមើលមិនជាចឹងហើយក៏បានស្លាប់បាត់ទៅកាលនឹង។

ក៖ អូ! ហើយចឹងកាលនឹងអ៊ុំបាននៅទាន់គាត់បានស្លាប់ដែរឬទេ?

ខ៖ កាលនឹងនៅទាន់តើ ។

ក៖ ហើយទៅពេលនឹងដូចជាអ៊ុំបានរៀបការជា១នឹងអ៊ុំប្រុសនឹងដោយស្រលាញ់គ្នាឬក៏ឪពុកម្ដាយគាត់ជាអ្នកដែលបានរៀបចំអោយសំរាប់អ៊ុំដែលគាត់បានទុកដាក់អោយ?

ខ៖ អត់កាលនឹងបានស្រលាញ់គ្នានឹងតែឪពុកម្ដាយនឹងគាត់ក៏ជាអ្នកដែលបានទុកដាក់អោយទៅណាកាលនឹងគាត់ក៏បានជាអ្នកដែលរើសអោយដែលនឹងហើយចឹងក៏បានយកគ្នាចឹងទៅ។

ក៖ ហឹសៗៗ

ខ៖ ជំនាន់នឹងវាមិនមែនដូចទៅនឹងជំនាន់សម័យឥឡូវនឹងទេកាលនឹងនោះ។

ក៖ ចាស!

ខ៖ ឥឡូវនឹងវាស្រាចតែចិត្តរបស់កូននឹងបើកូនគេស្រលាញ់ពីណានឹងគេបានទៅយកគ្នាហើយកាលនឹងវាចឹងនោះទេចឹងបានថាកាលពីជំនាន់មុនមកនឹងវាអត់ចឹងនោះទេតែថាម្ដាយនឹងគាត់បានថានឹងអោយទៅនរណាគេហើយកាលនឹងដឹងតែពីនុងនោះហើយកាលនឹង។

ក៖ ចាស!ចឹងការនឹងដូចជាអ៊ុំបានរៀបការនឹងនៅក្នុងជំនាន់អាពតឬក៏ក្រោយជំនាន់អាពតឬក៏បានរៀបការនឹងនៅមុនសម័យអាពតនឹងទៀត?

ខ៖ កាលនឹងបានរៀបការនឹងបានមុនសម័យអាពតនឹងទៀត។

ក៖ ចាស!ចឹងកាលនឹងអ៊ុំបានរៀបការនៅមុនសម័យអាពតចឹង?

ខ៖ ចាស់!

ក៖
ហើយចឹងកាលនឹងអ៊ុំបានរៀបការហើយនឹងអ៊ុំបានមានកូនដែរឬទេនៅក្នុងសម័យពពតដូចជាកាលនឹងអ៊ុំបាននឹងមានកូននឹងនៅក្នុងឆ្នាំណាដែល?

ខ៖ កាលនឹងអត់បានមានកូននឹងនៅក្នុងជំនាន់ពពតផងនឹងកាលសម័យនឹងនោះអត់មានទេ។

ក៖
ចឹងកាលនឹងអ៊ុំមានកូននឹងពេលដែលអ៊ុំបានដាច់ចេញពីសម័យពពតហើយមែនដែរឬទេ?អូចឹងកាលនឹងប្រហែលជាមិនមែននោះទេព្រោះអីកាលនឹងអ៊ុំបានរៀបការនឹងនៅក្នុងមុនសម័យពពតទៀតនឹង។

ខ៖ ចាស!មិនមែននោះទេ។

ក៖
ចឹងមានន័យថាពេលនឹងអ៊ុំប្រុសនឹងអ៊ុំស្រីបានរៀបការជាមួយនឹងគ្នានឹងបានមានកូននឹងនៅមុនជំនាន់អាពតទៀត?

ខ៖ ចាស!បានមុននឹងទៀនឹងនឹងកាលនឹង។

ក៖ ចាស!

ខ៖
ខ្ញុំមានបានកូនប្រុស១នាក់នឹងគេឥឡូវនឹងគេបានមានអាយុ៥០ឆ្នាំហើយនឹងបើគិតមកដល់ឥឡូវនឹងនោះ ហើយគេបានមានក្រុមគ្រួសារហើយនឹងគ្រួសារគេនឹងនៅរាងឆ្ងាយ។

ក៖ ចាសៗ!

ខ៖ ចាស!

កៈ ហើយអ៊ុំមានកូនបានត្រឹមតែម្នាក់នឹងទេ?

ខៈ មាន២នាក់ទៀត។

កៈ ហាក់អ៊ុំមានកូន២នាក់ទៀត?

ខៈ ចាសៗ

កៈ ចាស!

ខៈ ១នាក់នឹងមាននៅក្នុងមុនអាពតនោះ

កៈ ចាស!

ខៈ ហើយមានម្នាក់ទៀតនឹងបានកើតឡើងនឹងបានកើតពេលដែលបានចប់អាពតតែម្តងនឹង។

កៈ ចាស!ហើយដល់ពេលកូនស្រីគាត់បានកើតនៅក្រោយ?

ខៈ ចាស!!

កៈ ហើយចឹងសព្វថ្ងៃនឹងអ៊ុំកូនផ្សេងអីទៀតដែរឬទេកាលនឹង?

ខៈ អត់មានទេ។

កៈ ចាស!ហើយចឹងកាលនឹងអ៊ុំបានពពោះនៅក្នុងជំនាន់ពពតនឹងឬក៏យ៉ាងណាដែរកាលនឹង?

ខៈ កាលនៅក្នុងជំនាន់អាពពតនឹងខ្ញុំអត់មានពពោះអីផងនឹង។

កៈ អូ!ចឹងនៅក្នុងជំនាន់ពពតនឹងអ៊ុំអត់មានពពោះនោះទេ?

ខៈ ចាស!កាលនៅក្នុងជំនាន់ពពតនឹងខ្ញុំអត់មានពពោះអីនោះផង។

កៈ
ចុះពេលដែលហើយចុះកាលនឹងពេលដែលអ៊ុំប្រុសគាត់បានអនិច្ចកម្មទៅនឹងនៅក្នុងសម័យពពតហើយអ៊ុំបានមានកូន១នាក់ទៀត?

ខៈ កាលនឹងគាត់បានស្លាប់នឹងតាំងពីសម័យពពតនឹងមកម៉េចនឹងហាស។

កៈ នឹងហើយតែអ៊ុំមានកូន១នាក់ទៀតក្រោយសម័យពពត នឹងមានន័យថាអ៊ុំអឺ....

គៈ កូនមុននឹងគាត់មានប្ដីមុនហើយកូនក្រោយនឹងប្ដីក្រោយ១ទៀតចឹង
ប្រាប់គាត់អោយបានច្បាស់ទៅវាចឹង។

កៈ អូ!ចាស!ចឹងមានន័យថាអ៊ុំស្រីបានរៀបការនឹងបានចំនួន២ដងត្រូវទេអ៊ុំស្រី?

ខៈ ចាស១!

កៈចាស! ហើយចុះអ៊ុំប្រុសស្វាមីរបស់អ៊ុំនៅចុងក្រោយនឹងគាត់មានឈ្មោះអ្វីគេដែរទៅអ៊ុំ?

ខៈ អត់ទេ!

កៈ ហឺ !ចាស!

ខៈ ហឺ!

កៈ ចាស!ដូចជាគ្រួសាររបស់អ៊ុំដូចជាអឺ...ឪពុកម្ដាយរបស់អ៊ុំគាត់មានឈ្មោះអ្វីដែរ?

ខៈ ហឺ!សួរតាំងពីឪពុកម្ដាយដែលគាត់បានស្លាប់ទៅបាត់ហើយនឹង។

កៈ
ចាស!ដោយសារតែអឺការងារមួយនឹងគេចង់ក្រងប្រវត្តិរបស់ប្រជាជនកម្ពុជាដូចជាជាក់ស្ដែងអ៊ុំចឹងពេលដែលបានផុតពីជំនាន់របស់អ៊ុំចឹងទៅនឹងគេនឹងបានរក្សាវាទុកថាគេនឹងបានដឹងអំពីវង្សារ១នឹងបានចឹងណាអ៊ុំ។

ខៈ ចាស!

កៈ
ចាស!ចឹងគេអាចនឹងបានដឹងថាលោកតាគាត់ជីតាជីលួតនឹងគាត់មានឈ្មោះអ្វីគេដែរចឹងណាអ៊ុំ!!

ខៈ ចាស!ខ្ញុំវាមិនសូវបាននឹងដឹងថាដូចជាជីតាជីលួតអីនឹងហាហាហាហឺស

កៈ ចាស!ចឹងអ៊ុំមានបានចាំឈ្មោះត្រឹមឪពុកនឹងម្ដាយរបស់អ៊ុំដែរឬទេ?

ខ៖ ថីមិនបានចាំម៉ែរបស់ខ្ញុំនឹងនោះ។

ក៖ ចាស!គាត់មានឈ្មោះអ្វីដែរទៅ។

ខ៖ ចាស!គាត់មានឈ្មោះដែលត្រូវនឹងនាមត្រកូលរបស់ខ្ញុំនឹងហើយមានឈ្មោះថា ច្រឹកនឹងហើយ ចាសឪរបស់ខ្ញុំនឹងហើយគាតមានឈ្មោះថា ច្រឹកហើយចំពោះឈ្មោះម្តាយរបស់ខ្ញុំវិញនឹងគាត់មានឈ្មោះថាលោកយាយ ផៃ។

ក៖ ចាស!លោកយាយ ផៃ?

ខ៖ ចាសៗ!

ក៖ ចាស!ហើយចុះឈ្មោះពេញរបស់គាត់នឹងវិញ?

ខ៖ គាត់មានឈ្មោះតែប៉ុណ្ណឹង អត់មានឈ្មោះណាទៀតនោះទេ។

ក៖ នាមត្រកូលរបស់គាត់ណាអ៊ុំ!!

ខ៖ អូ !នាមត្រកូលខ្ញុំមិនបានចាំផង។

ក៖ អូ!ហើយចុះកាលដែលគាត់បានអនិច្ចកម្មទៅនឹងគាត់អនិច្ចកម្មទៅនឹងបានប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖ អូ!វាយូរហើយ។

ក៖ តាំងពីមុនសម័យពពតទៀតអ៊ុំ?

ខ៖ មុននឹងទៀត។

ក៖ ចាស!សោកស្តាយមែនទែន។ហើយចុះអ៊ុំស្រីមានបងនឹងប្អូនបានប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូននឹងមានតែ២នាក់នឹង។

ក៖ សព្វថ្ងៃនឹងគាត់នៅមានជីវិតដែរឬទេអ៊ុំ?

ខ៖ បងប្អូនរបស់ខ្ញុំនឹងគាត់នៅមានជីវិតនៅតើ សព្វថ្ងៃនឹងគាត់មានផ្ទះនៅឯមុខនឹងនោះ។

កៈ អូ!គាត់នៅជិតនឹងដែរ។

ខៈ ចាស!

កៈ គាត់ម្នាក់ៗនឹងគាត់មានឈ្មោះអ្វីដែរទៅអ៊ុំ?

ខៈ គាត់មានឈ្មោះថា ផាត់។

កៈ គាត់ជាកូនប្រុសឬក៏ស្រីអ៊ុំ?

ខៈ គាត់ជាស្រីចាស ប្រុសនឹងស្រីនឹងបងប្អូនតែ២នាក់។

កៈ ចាស!ចឹងនៅជិតគ្នាចឹងបានស្រួលហើយព្រោះអីបានដឹងសុខនឹងទុក្ខគ្នា។

ខៈ ចាស!

កៈ ចុះអ៊ុំអត់មានបងប្អូនផ្សេងៗទៀតដែលគាត់បានស្លាប់នៅក្នុងជំនាន់ពពតទេន៎អ៊ុំ?

ខៈ អត់ផងអត់មានផង។

កៈ អូ!ល្អមែនទែនចឹង ចឹងកាលនឹងអ៊ុំសំណាងហើយកាលនឹង។ហោសៗៗ

ខៈ ចាស!

កៈ ហើយកាលនឹងតើគេបានធ្វើការជំលៀសគ្រួសារអ៊ុំទៅដល់ណាដែរ?

ខៈ
កាលនឹងគេមិនបានជំលៀសខ្ញុំនឹងទៅដល់ណានោះទេកាលនឹងគេបានត្រឹមតែធ្វើការជំលៀសខ្ញុំនឹងពីត្រឹមនឹងទៅដល់កោះតូចនៅឯគៀនឃ្លាំងយើងនឹងហើយមកវិញនឹងក៏បានចូលទៅក្នុងស្រុកហើយក៏បានចប់បណ្តោយហើយបើថាខ្លះចឹងទៅគេបានធ្វើការជំលៀសនឹងទៅដល់ឯបាត់ដំបងឯនោះកាលនឹងទៅដល់ឯបាត់ដំបង់អីនឹងទៅតែចំណែកខ្ញុំនឹងអត់ទេ
នៅតែក្នុងតំបន់នឹង។

កៈ ចាស!ហើយចឹងកាលនឹងគេបានប្រើអោយអ៊ុំបានធ្វើអ្វីខ្លះទៅកាលនឹង?

ខៈ កាលនឹងបានប្រើអោយទៅធ្វើចំការអីចឹងជាធម្មតាអីនឹងចឹង ដាំអីៗចឹងទៅ។

កៈ
ហើយកាលនឹងគេបានប្រើអ៊ុំអោយធ្វើការងារនឹងបានពីម៉ោងប៉ុន្មានដល់ប៉ុន្មានដែរកាលនឹង?

ខៈ
ធ្វើការនឹងពេលព្រឹកឡើងចឹងទៅម៉ោង៧អីនឹងទៅហើយពេលដល់ម៉ោង១១អីនឹងបានត្រលប់មកវិញមកកាលនឹងហើយដល់ពេលថ្ងៃឡើងនឹងបានចុះទៅធ្វើការទៀតទៅកាលនឹង។

កៈ
ចាស!ហើយចុះកាលនឹងអ៊ុំនៅក្នុងសម័យពពតនឹងអ៊ុំបានជួបនឹងការលំបាកអ្វីគេខ្លះដែរកាលនឹងដូចជាពេលនឹងគេមានបានធ្វើបាបអីអ៊ុំនោះទេកាលនៅក្នុងជំនាន់ពពតនឹង?

ខៈ អត់ផង
ព្រោះអីកាលនឹងពេលដែលនៅគ្នុងកោះនឹងគេមិនទៅបានធ្វើបាបអីយើងនោះទេកាលនឹងបើគេវិញនៅឆ្ងាយៗនឹងបានគេបានធ្វើបាបហើយគេប្រើអីចឹងទៅតែចំណែកឯនោះនឹងនេះនឹងអត់មានគេបានប្រើអីនោះទេគ្រាន់តែគេបានប្រើអោយទៅដកស្ទូងសាបអីចឹងធម្មតាចឹងទៅ។

កៈ ចាស!

ខៈ នឹង!

កៈ ហើយចឹងកាលនឹងចំការនឹងគេបានប្រើអ៊ុំអោយទៅដាំអ្វីគេខ្លះទៅកាលនឹង?

ខៈ គេបានប្រើទៅអោយទៅដាក់ដាំនៅចំការនឹងមានដាក់ដាំទ្រព្យទៅ ដាំល្ពៅអីចឹងទៅ
ដាំដើមអីៗនឹងដើម្បីនឹងយកមកអោយយើងនឹងបានហូបសំរាប់យើងនឹងដដែលៗនឹង
ហើយជូនចឹងទៅគេបានអោយទៅដាក់ដាំនៅឯណាចឹងទៅ។

កៈ
អូ!ចឹងកាលនឹងគេបានប្រើអោយអ៊ុំបានទៅដាក់ដាំហើយនឹងគេបានយកមកអោយយើងវិញទៀត។

ខ៖
ចាស!ចឹងគេបានអោយយកមកអោយយើងវិញនឹងគេមិនបាននឹងយកទៅណានោះទេកាលនឹងគេមិនបានធ្វើស្អីយើងនឹងនោះទេកាលនឹងនោះ។

ក៖ ចាស!ចឹងកាលនឹងគេបានអោយអ៊ុំនឹងនូវរបបជាបាយឬក៏ជាបបរដែលកាលនឹងនោះ?

ខ៖ គេបានអោយខ្ញុំនឹងជាបបរ
ហើយចឹងកាលនឹងពេលខ្លះទៅគេបានអោយយើងនឹងហូបបាយចឹងទៅហើយពេលខ្លះចឹងទោគេបានអោយយើនឹងហូបបបរចឹងទៅកាលនឹងវាមិនបានជាសូវទៀងអីចឹងនោះទេ។

ក៖ ហឹសៗៗ

ខ៖
ហឹសៗៗកាលនឹងគេបានអោយយើងហូបនឹងច្រើនតែបបរទេវាមិនសូវបានបាយសំរាប់ហូបទេកាលនឹងហេសៗៗ

ក៖ ចឹងកាលនឹងគេបានអោយអ៊ុំបានហូបបានប៉ុន្មានពេលដែលកាលនឹង?

ខ៖ ចាស!!

ក៖ កាលនឹងគេបានអោយអ៊ុំបានប៉ុន្មានពេលដែល?

ខ៖
កាលនឹងគេបានអោយអ៊ុំនឹងបានហូបតែពេលព្រឹកនឹងពេលល្ងាចនឹងបានពេលព្រឹក១ពេលទៅហើយពេលល្ងាចនឹងបាន១ពេលទៀតនឹងទៅកាលនឹង។

ក៖ហើយចឹងពេលថ្ងៃនោះ?

ខ៖ ពេលថ្ងៃនឹងកេមិនបានអោយយើងនឹងបានហូបទៅកាលនឹងអត់បានទេ។

ក៖ អូ!

ខ៖

ដល់ពេលគេអោយយើងនឹងបានតែម៉ោងព្រឹកនឹងបាន១ពេលចឹងទៅហើយពេលម៉ោង១១នឹងបាន១ពេលទៀតចឹងទៅតែប៉ុណ្ណឹង។

ក៖

ចាស!ហើយចុះអ៊ុំកាលនឹងអ៊ុំបានពិសារបានឆ្អែកដែលឬទេបើគេបានអោយអ៊ុំពិសារបបរចឹង?

ខ៖

ចាស!បានឆ្អែកតើកាលនឹងគេមិនបានអោយយើងនឹងទៅវាស់ដាក់នឹងវែកអីនឹងនោះទេកាលនឹងគេបានអោយយើងនឹងបានហូប១ឆ្អែកៗនឹងណា។

ក៖

ហើយចឹងកាលនឹងដូចជាអ៊ុំនឹងបានសំណាងហើយចឹងព្រោះបើតាមខ្ញុំធ្លាប់បានស្ដាប់មកកាលនៅក្នុងសម័យនឹងគេបានអោយបបរជារបបនឹងបានតែ៣វែកអីនោះទេកាលនឹង។

ខ៖ ចាស!!

ក៖ ហើយចឹងកាលនឹងបបរនឹងឡើងរាវតែម្ដងហើយវាគ្មានអីនឹងបានឆ្អែកនោះទេកាលនឹង។

ខ៖ចាស!

ក៖ ចឹងកាលនឹងវាមិនបានឹងឆ្អែកនោះទេពេលដែលបានដូសមកនឹងវាឡើងរាវកក្លូក។

ខ៖ ចាស!ហឹស!

ក៖ ចឹងភូមិនេះរាងស្រួល។

ខ៖ នឹងហើយសហាករអីនឹងគាត់រាងស្រួលអោយយើងនឹងបានហូបឡើងឆ្អែកៗ។

ក៖

ចុះកាលនឹងចំពោះគេប្រើវិញនឹងគេបានប្រើអ៊ុំដល់បាក់កំលាំងនឹងបានប្រើអ៊ុំអោយធ្វើការងារខ្លាំងៗដែរឬទេ?

ខ៖
អត់ទេនៅក្នុងភូមិនឹងអត់មានគេប្រើអីនឹងខ្លាំងនោះទេអ្នកនៅក្នុងភូមិនឹងនោះព្រោះអីកាលនឹងគេបានប្រើអោយទៅណាទេដូចជាចំពោះតែអ្នកខ្លះទេណាដែលគេបានប្រើទៅបឹងនឹងតែចំណែកខ្ញុំវិញនឹងមិនបានទៅនឹងគេនោះទេ។
ចាសគេបានប្រើខ្ញុំនឹងអោយតែទៅធ្វើចំការអីនឹងតែបន្តិចបន្តួចអីចឹងទៅ។

ក៖ ចាសហ៊ឺស ហើយចឹងដល់ពេលចាស

ខ៖
បើកាលនឹងបើបានសំភាសន៍អ្នកដែលគេបាននៅនឹងខេត្តបាត់ដំបងអីនឹងបានគេរាងច្បាស់ហើយបើខ្ញុំនឹងវានៅរាងថារាងបាននៅតែនឹងកោះនឹងទេ។

ក៖
ចាស!ចំពោះរឿងនឹងគឺថាជីវិតនឹងអ្នកដែលរស់នៅនឹងលើកោះនឹងហើយនៅនឹងកន្លែងផ្សេងនឹងវាមានជីវិតកាលនឹងវាមានលក្ខណៈផ្សេងៗគ្នា។

ខ៖ ចាស!!

ក៖ ចាស!មានជីវិតរស់នៅកាលនឹងវាខុសៗគ្នាចឹងណាអ៊ុំ!

ខ៖ ចាស!

ក៖
ចាស!ចឹងចំពោះជីវិតរបស់អ៊ុំនឹងកាលនឹងអ៊ុំមានបទពិសោធន៍ជីវិតកាលនឹងមិនសូវមានការលំបាកអីនោះទេកាលនឹង។

ខ៖ ចាស!អត់ទេ ចាស។

ក៖ចាស!អ៊ុំហើយចុះអ៊ុំកាលនៅក្នុងសម័យនឹងអ៊ុំមានបានធ្លាប់បានឃើញអាពតនឹងគាត់មានយកមនុស្សទៅវៃចោលដែរឬទេកាលនឹង?

ខ៖ ចាស!អត់ផងកាលនឹង។

កៈ ចាស!ចឹងកាលនឹងអ៊ុំអត់ដែរបានឃើញទេ?

ខៈ ចាស!អត់ដែរផង។

កៈ
កាលនឹងអ៊ុំមានសំណាងមែនទែនកាលនឹងព្រោះអីគេមិនសូវបានធ្វើបាបហើយនឹងគេបានអោយអ៊ុំញ៉ាំអីបានគ្រាប់គ្រាន់ទៀត។

ខៈ ចាស!!

កៈ
ចាស!ចឹងអ៊ុំកាលនៅក្នុងសម័យពពតនឹងតើអ៊ុំបានចង់ចាំអីគេខ្លះកាលនឹងតែពីក្នុងសម័យពពតនឹងមករហូតមកដល់ឥឡូវនឹងដែលធ្វើអោយអ៊ុំបានចង់ចាំវាឡើងនឹងបាននឹកឃើញដល់ទិដ្ឋភាពនឹងវាមានអីគេខ្លះទៅ?

ខៈ
ខ្ញុំនឹងដូចកាលនឹងអត់មានអីសោះកាលនឹងខ្ញុំនឹងដូចជាធម្មតាកាលនឹងព្រោះអីគេនឹងមិនមានបានទៅធ្វើបាបអីដល់យើងផងនឹងចឹងទៅកាលនឹងខ្ញុំវាបានដូចជាធម្មតាហើយចឹងកាលនឹងពេលដែលខ្ញុំនឹងបានមកវិញនឹងខ្ញុំនឹងក៏បានហូបហើយទៅពេលដែលក្រោកឡើងនឹងទៅធ្វើការហើយធ្វើការងារហើយចឹងទៅក៏បានទៅហូបបបរអីនឹងហើយបានហូបទៀតក៏បានហើយអីអស់ចឹងក៏បានទៅងុតទឹកចូលដេកទៅតែប៉ុណ្ណឹង។

កៈ ហេសៗ

ខៈ តែប៉ុណ្ណឹងកាលនឹងអត់មានអីទៅពិបាកនោះផង។

កៈ
ចាស!អ៊ុំហើយចឹងកាលនៅក្នុងសម័យពពតនឹងអ៊ុំមានបានធ្លាប់នឹងគិតថាចង់អោយវាបានរួចដាច់ចេញវិញមកនឹងឆាប់ៗនឹងភ្លាមៗអីនឹងអត់មានទេណ៎អ៊ុំ?

ខៈ ចាស!

កៈ ចឹងអ៊ុំអត់មានដែលធ្លាប់បានគិតចឹងទេ?

ខ៖
កាលនឹងបានធ្លាប់គិតដែលនឹងថាហឺមិនបានដឹងថានៅថ្ងៃណាខែណាបានវាចប់ចឹងទៅណាកាលនឹងព្រោះអីចង់តែអោយវានឹងបានចប់ទៅណាកាលនឹងព្រោះអីវាបានស្រួល។

ក៖
ចាស!ហើយបន្ទាប់មកនឹងកាលនៅក្នុងសម័យនឹងអ៊ុំមានធ្លាប់ឈឺដែលឬទេកាលនៅគ្នុងសម័យនឹង?

ខ៖ កាលនឹងខ្ញុំអត់សូវបានឈឺផងកាលនឹង។

ក៖ ចឹងកាលនឹងមានន័យថាអត់សូវជាឈឺនឹងកាលនឹងមានតែអ៊ុំធ្លាប់បានឈឺហើយចឹង?

ខ៖ ចាស!

ក៖ ចឹងអ៊ុំមានធ្លាប់នឹងឈឺអ្វីដែរ?

ខ៖
ហឺ!កាលនៅក្នុងជំនាន់នឹងមានថ្នាំពេទ្រអីនឹងគេដែលនឹងពេលដែលយើងឈឺទៅគេបានអោយយើងលេបនឹងដែរ។

ក៖
ចឹងកាលនឹងគេមានបានអោយយើងនឹងនូវថ្នាំពេទ្រអីនឹងសំរាប់យកមកអោយយើងនឹងបានលេប។

ខ៖ ចាស!

ក៖ ហើយចឹងកាលនឹងអ៊ុំមានបានធ្លាប់ឈឺដែលឬទេកាលនឹង?

ខ៖ អត់ផង

ក៖ ហឺ!
ហើយបន្ទាប់មកទៀតនឹងខ្ញុំក៏ចង់ដឹងទាក់ទងទៅនឹងរឿងរបស់អ៊ុំកាលនៅពីក្មេងឡើយនឹងតើអ៊ុំធ្លាប់នឹងមានក្តីស្រមៃចង់ក្លាយជាអ្វីដែរឬទេអ៊ុំ?

ខ៖ ហឺសៗៗខ្ញុំនិងគ្មានបានស្រមៃអីទេសព្វថ្ងៃនឹងបើវាមើលទៅវាគ្មានអីនឹងផង។

ក៖ ចាស!ចឹងអ៊ុំអត់មានក្ដីស្រមៃថាពេលដែលអ៊ុំបានធំឡើងនឹងអ៊ុំនឹងចង់ធ្វើជាអ្វីទេហ៎?

ខ៖
កាលដែលនៅនឹងក្មេងៗនឹងវាមិនទាន់នឹងថានឹងចង់ធ្វើអ្វីនឹងទេកាលនឹងវាមិនដឹងអីហេសៗៗ

ក៖ ចាស!

ខ៖ ហេ!

ក៖
ហើយកាលនឹងដូចជាពេលដែលអ៊ុំនៅពីក្មេងៗនឹងអ៊ុំមានបានធ្លាប់ចូលចិត្តដូចជាការលេងល្បែងអីនឹងដូចជាកាលដែលអ៊ុំស្រីនៅពីក្មេងៗនឹងអ៊ុំមានបានចូលចិត្តនឹងលេងល្បែងនឹងលេងgameអីទេអ៊ុំ?

ខ៖
លេងgameអីនៅក្នុងទូរស្សន៍នឹងកាលនឹងមានបានតែល្បែងដូចជាផ្ទាត់កៅស៊ូអីនឹង។ហេសសៗៗកាលនៅក្មេងៗនឹងវាមិនទៅជាចេះអីហេសៗៗដូចតែនៅក្មេងសព្វថ្ងៃនឹងចឹង។
ពេលនឹងបានលេងនឹងចឹង។

ក៖ ហើយចឹងកាលនឹងអ៊ុំបានលេងនឹងដូចជាបានលេងផ្ទាត់កៅស៊ូអីនឹង?

ខ៖ ចាស!មានលេងដូចជាផ្ទាត់កៅលីអីចឹងដែរទៅ។

ក៖ ចាស!អ៊ុំហើយកាលនឹងលេងកៅលីនឹងគេលេងយ៉ាងម៉េចដែរទៅអ៊ុំ?

ខ៖ កាលនឹងលេងនឹងគេបានទៅជីកដីឡូទៅ
ហើយពេលដែលបានបោះទៅនឹងបានចូលក្នុងឡូនឹងទៅហឺសៗៗហាហាៗៗ។

ក៖ ចឹងយើងត្រូវជីកជាឡូហោះ?

ខ៖
គេជីឡូនឹងប្រហែលជាតែប៉ុនៗនឹងនេះចឹងហើយទៅពេលដែលបានជីកហើយទៅនឹងគេបាន
អោយយើងនឹងបោះគ្រាប់ខ្ញៅនឹងចូលទៅ។

ក៖ គេបានប្រើខ្ញៅនឹងមែនទេអ៊ុំ?

ខ៖ អានឹងខ្ញៅនឹងគេបានលេងអាស្ពីនឹងគេទេ។

ក៖ គេហៅបាយខុំ។

ខ៖ ចាស!គេហៅថាបាយខុំ។

ក៖ ចាស!

ខ៖
ចាស!ហើយចឹងគេបានដាក់ដៃអីនឹងអោយយើងនឹងបានវៃអីចឹងទៅមកហោៗៗកាលនឹងក្មេងជំ
នាន់នោះ។ វាបានចង់នឹងភ្លេចភ្លាំងអីអស់ទៅហើយនឹងសព្វថ្ងៃនឹងណោះ ។

ក៖ ចាស!ខ្ញុំឮមានអាយុបាន៦០ឆ្នាំហើយ។

ខ៖ ចាស!

ក៖ ចាស!តែអ៊ុំនៅមានសាច់ឈាមនៅចាំ អ៊ុំនៅមានសាច់ឈាមនៅចាំហោសសៗៗ

ខ៖
ចាស!ប៉ុន្តែប៉ុន្មានថ្ងៃនឹងខ្ញុំបានលើសឈាមអីនឹងវារាងធ្វើអោយយើងនឹងឡើងស្រវាំៗភ្នែកយើ
ងនឹង។ហើយវាយើងនឹងចេះតែខំខាលសូត្យទៅ
ចេះតែទៅខាលសូត្យនឹងយកទៅអោយគេចឹងទៅមុខរបរនឹងខ្ញុំស៊ីឈ្នួលអោយគេទេ
ខ្ញុំស៊ីឈ្នួលអោយគេនឹង។

ក៖ ចាស!ហើយទៅមុខរបរ១នឹងក្នុង១ថ្ងៃអីនឹងអ៊ុំអាចរកបានប៉ុន្មានដែរ?

ខ៖ នេះ១កាលីនឹងខ្ញុំអាចរកបាន២០០០០រអានឹងបាន១គីឡូកន្លះ ។

ក៖ អូ!នឹងពេលដែលអ៊ុំធ្វើបាន៥ថ្ងៃចឹងវា បាន១គីឡូរនឹងបាន៥០០០០រ។

ខ៖ បានតែ៣០០០០រនឹង។

ក៖ ៣០០០០រនឹង!

ខ៖ ចាស!!

ក៖ ហើយត្រូវធ្វើវា៥ថ្ងៃ?

ខ៖ ធ្វើបាន៥ថ្ងៃ។

ក៖ ជិតបាន១០០០០រ។

ខ៖
អានឹងវាមានការខាលសូត្រនឹងវាចំអារាងស្រួលហើយបើថាវានៅចំអារាងពិបាកនឹងវាមិនបាន
ប៉ុណ្ណឹងនោះទេ។

ក៖ ចាស!!

ខ៖ ចាស!អានឹងវាចំសូត្រវារាងស្រួលៗខាល។

ក៖
ចាស!ហើយចឹងទៅអ៊ុំបានធ្វើការខាងខាលសូត្យនឹងអ៊ុំបានធ្វើការងារ១នឹងបានពីម៉ោងប៉ុន្មានដ
ល់ម៉ោងប៉ុន្មានដែរ?

ខ៖ អូ!ខ្ញុំបានក្រោកឡើងនឹងហើយក៏បានចាប់ធ្វើទៅអោយគេទៅ
ហើយធ្វើធ្វើនឹងពេលដេលយើងបាននឹងចាប់ក្រោយឡើងនឹងហើយក៏បានចាប់ផ្តើម់ធ្វើវាទៅ។

ក៖ ចាស!អ៊ុំហើយចឹងអ៊ុំមានបាននឹងលក់អ្វីគេខ្លះដែរអ៊ុំ?

ខ៖
ហឺទឹកស្ទឹងនឹងតែជ្រក់នឹងទៅបានតែប៉ុណ្ណឹងក្នុង១ថ្ងៃអឺនឹងវាបាន១ថ្ងៃអិនឹងបាន១០០០០រជាង
ដែរអឺចឹងទៅហោសៗៗៗ។

ក៖ ហោសៗៗ

ខ៖
ហីសៗៗគ្រាន់បានយើងយកទៅសន្សំទៅគ្រាន់បានតែចាយនឹងពេលដែលយើងយកវាទៅវិញនឹងយកទៅវិញនឹងវាមិនចង់នឹងគ្រាប់ផងនឹង។

ក៖ ចឹងអ៊ុំបានធ្វើការផ្សំគ្នាហើយដោយសារមានការលក់របរបន្តិចបន្តួចបន្ថែមទៀតចឹងណាអ៊ុំដែលអ៊ុំបានលក់ឥវ៉ាន់ចាប់ហួយនឹងផងហើយនឹងខាលស្លូត្រនឹងទៀតនឹង។

ខ៖ ចាស!

ក៖ហើយចឹងអ៊ុំត្រូវចែកពេលគ្នាធ្វើ។

ខ៖ ចាស!ចែកនឹង

ក៖ ហើយសព្វថ្ងៃនឹងអ៊ុំមានមុខរបរតែប៉ុណ្ណឹងទេណោអ៊ុំ?

ខ៖ចាស!មានតែប៉ុណ្ណឹងនោះទេហើយអានឹងបាននឹងពេលខ្លះទៅកូនយើងវាបានយកមកអោយអីខ្លះដែលនឹងទៅ។

ក៖ ចុះកាលពីមុនឡើយនឹងអ៊ុំមានមុខរបរអីផ្សេងទៀតដែលឬទេ?

ខ៖ មុននឹងអត់មានផងៗក

ក៖ ចាស!ដូចជាកាលពីដាច់កាលពីជំនាន់អាពតមកនឹង។

ខ៖ កាលពីជំនាន់នឹងមកនឹងខ្ញុំមានធ្វើការងារសុទ្ធតែត្បាញ់អំបោះនឹង សុទ្ធតែត្បាញអំបោះ។

ក៖ ចាស!តែត្បាញអំបោះនឹងទេ?

ខ៖
មានការងារតែត្បាញ់នឹងពេលនឹងខ្ញុំបានត្បាញអំបោះនឹងបាន១ក្បិននឹងបាន១០០០០រជាងកាលនៅជំនាន់នឹងនោះកាលដែលគេបានចប់មកនឹងបានតែប៉ុណ្ណឹង។

ក៖
ចាស!ចឹងកាលនៅក្នុងជំនាន់នឹងអ៊ុំអាចនឹងធ្វើការត្បាញ់បានក្នុង១ក្បិនចឹងអ៊ុំអាចត្បាញបានប៉ុន្មានដែលដូចជាបានប៉ុន្មានសំពត់ដែល?

ខ៖ កាលនឹងបាន២ថ្ងៃនឹងគេបានត្បាញ់នឹង១ក្បិននឹង។

ក៖អូ!បាន២ថ្ងៃនឹងបាន១ក្បិន។

ខ៖ចាស!

ក៖ចាស!បាន១០០០០រជាងនឹងកាលនឹងលុយវាបានថ្លៃ។

ខ៖ ចាស!កាលនឹងវាបានថោក។ ចាសកាលនឹងលុយវាបានថ្លៃ។ មើលរបស់នឹងឥឡូនឹងវាមិនបានជាចឹងនោះទេកាលនឹងមានតែ២០០០រទៅ៣០០០០នឹងបានស៊ីឆ្អែកហើយ។ហេសៗៗ

ក៖ ចាស!ហើយកាលនឹង១០០រកាលនឹងខ្ញុំយក១០០រនឹងយកទៅទិញអីនឹងបានញ៉ាំហើយតែសព្វថ្ងៃនឹងយក១០០រទៅទិញអីនឹងវាមិនបានញ៉ាំអីបានទេ។

ខ៖ ចាស!កាលនឹងវាចេះតែបានហើយកាលនឹងបានត្រឹមតែ១កាកមួយរយអីនឹងវាបានតែសព្វថ្ងៃ១០០០០រអីនឹងមិនដឹងជាយ៉ាងម៉េចផងនឹងមិនទៅចាយរួចផងនឹងវាគ្រាន់តែបានម៉ាចំណីស៊ីអីនឹងចឹងទៅបើគិតទៅវាដាច់បាច់ហើយ២០០០០រនឹងរួចជាស្រាច។

ក៖ ចាស!ចឹងចំណាយច្រើនហើយចឹងណ៎។

ខ៖ ចាស!អានឹងមាត់របស់ខ្ញុំនឹងវាតិចទេកាលនឹងវាបានញ៉ាំនឹងបានតែ៣នាក់នឹងចៅទេណា។

ក៖ ចាស!

ខ៖ ចាស!ប៉ុន្តែហ្វបនឹងវាច្រើនមិនដែលថាចេះអត់អីនឹងគេនោះទេ។

ក៖ចាស!

ខ៖ ចាស!

ក៖ ចាស!ចឹងអ៊ុំសព្វថ្ងៃនឹងអ៊ុំនៅមានគ្នាប៉ុន្មាននាក់ដែរទៅអ៊ុំ?

ខ៖ ចាស!មានតែ៣នាក់នឹងចៅនឹង។

ក៖ គាត់មានឈ្មោះអ្វីខ្លះទៅអ៊ុំ?

ខ៖ចាស!

ក៖ គាត់មានឈ្មោះអ្វីខ្លះទៅអ៊ុំ?

ខ៖ ឈ្មោះដូចៗតែគ្នានឹងគេមានម្ដាយនឹងកូននឹងឯង។ហើសៗៗ

ក៖
ចាស!ហើយអីអ៊ុំហើយចឹងកាលដែលអ៊ុំបាននឹងដាច់ពីអាពតមកនឹងអ៊ុំអត់មានបានធ្វើអ្វីក្រៅអីត្បាញ់នឹងទេអ៊ុំ?

ខ៖ ចាស!អត់មានធ្វើអ្វីទេមានតែការងារធ្វើចំការអីនឹងនឹងមានការត្បាញ់អីនឹងចឹងទៅ។

ក៖ អូ!នឹងចឹងកាលនឹងអ៊ុំមានបានធ្វើការងារចំការដែលហោះ?

ខ៖
ចាស!មានកាលជំនាន់នឹងមានដីចំការតែមកដល់ពេលឥឡូវនឹងយើងគ្នាដីចំការអីនឹងគេទៀតនោះទេព្រោះអីយើងបានលក់យកទៅអោយគេនឹងអស់បាត់ទៅហើយនឹងព្រោះអីកាលនឹងយើងនឹងវាក្រីក្រចឹង។ (សួរចៅទៅណានឹងមីអូន?ទៅហៅពេទ្យមែន?)

ខ៖ បើទៅហៅនឹងប្រាប់គាត់ថាយាយមិនទាន់បានស្រលះភ្នែកនោះទេ។

ក៖ ចាស!អ៊ុំបានឈឺហ៎?

ខ៖
ចាស!ខ្ញុំថ្ងៃមុននឹងបានទៅវាស់ស្ទង់មើលនឹងបានដឹងថាឈាមនឹងបានតែ២០ហើយនឹងបេះដូងនឹងវាបាន៩០ជាង។

ក៖ ចាសអូ!

ខ៖ វាចេះតែស្រវាំងនឹងភ្នែកនឹង

ក៖ ចាស!

ខ៖ ហើយចឹងពេលដែលពេទ្យគេមកនឹងចាំខ្ញុំទៅវាស់វាមើលម្តងទៀតមើល។

ក៖ ចាស!

ខ៖ ចឹងបានចង់នឹងថាវានឹងបានស្រក់អីដែលឬនៅ។

ក៖ ចាស!ចឹងខ្ញុំសូមទោសដល់អ៊ុំផងដែលសំភាសន៍ចំពេលដែលអ៊ុំមិនសូវស្រួលខ្លួនចាស។

ខ៖ ចាស!ខ្ញុំនឹងវាបានមិនសូវជាបានស្រួលខ្លួននឹងបានជាង២ទៅ៣ថ្ងៃហើយនឹង
ព្រោះអីប៉ុន្មានថ្ងៃនឹងគេចេះតែមកបង្ខំយកសូត្រយកទៅអោយជាងកីគេនោះអី។

ក៖ ចាស!

ខ៖ ព្រោះអីជាកីគេនឹងវាច្រើននាក់ចឹង។

ក៖ ហឺ!

ខ៖ ហើយគេបានអោយយើងនឹងបានស៊ីឈ្នួលនឹងបានក្នុង១ក្បិននឹងបានជាង៥០$
ហើយគេយកទៅលក់នឹងបានទៅដល់១០០$នៅក្នុង១ក្បិនគេនឹង។

ក៖ ចាស!

ខ៖ ហើយចឹងយើងនឹងក៏បានខាលទៅថាតើក្នុង១កាលីនឹងអោយគេទៅ។

ក៖ អូ!

ខ៖ ចឹងណាបានជាគេនឹងចេះតែបង្ខំអោយយើងនឹងខាល
ហើយពេលខ្លះអីចឹងទោបានកូននឹងគេបានជួយអីខ្លះចឹងទៅ។

ក៖ ចាស!

ខ៖ ហើយបើថាយើងនឹងទៅអង្គុយហើយងើបឡើងនឹងឡើងវិលតែម្តង។

ក៖ ចាស!

ខ៖ ចាស!

ក៖
ហើយចឹងអានឹងគេបានដាក់ជាtargetអោយយើងមែនអានឹងដូចថាគេបានអោយយើងគិតជាចំនួនថាពេលក្នុង១ខែៗនឹងគេត្រូវតែអោយយើងនឹងបានខាលបានប៉ុណ្នឹងៗមែន?

ខ៖ អត់ផង។

ក៖ ចុះមូលហេតុអ្វីបានជាគេមកបង្ខំយើងបាន?

ខ៖ អានឹងដូចថាពេលដែលជើងកីអីនឹងទៅ
គេនឹងបានខាលចេកៗហើយអោយយើងនឹងខាលបាន១ក្បិនអីនឹងបាន១រង់ចឹងណា។
បាន១ក្បិនចឹងទៅបាន១មុខផ្សេងចឹងទៀតទៅហើយយកទៅអោយគេនឹងបន្តមកទៀតទៅ។

ក៖ អូ!ចឹងបានគេនឹងបង្ខំយើង។

ខ៖
នឹងហើយចឹងបានជាគេនឹងបង្ខំយើងហើយនិយាយទៅពីថៅកែលគេនឹងអត់សូវនៅផ្ទះគេច្រើនតែទៅដើរលេងចឹង។

ក៖ ហេសៗៗ

ខ៖ ព្រោះអីគេនឹងជាអ្នកដែលមានលុយ
ចឹងហើយគេមានលុយនឹងគេបានទៅដើរលេងចឹងទៅគេមាននឹងដោយសារតែដីគេដែលនឹង។

ក៖ ចាស!បានសោកស្តាយដីអ៊ុំមានដែរប៉ុន្តែមានលក់អស់រលីង។

ខ៖ ចាស!ចឹងបានថាដីមានដែលនឹងតែបានលក់ទៅអោយគេបានត់ទៅហើយនឹង។
ចឹងហើយនឹងបានថានឹងបើគេនឹងបានមានដីហើយនឹងគេនឹងបានលក់ទៅអោយគេនឹងដែលដូចតែគ្នាចឹងទៅ។

ក៖ ចាស!ព្រោះអីកាលនៅនឹងជំនាន់នឹងវាលក់បានថ្លៃ។

ខ៖ ចាស!បើនៅក្នុងជំនាន់របស់ខ្ញុំនឹងវាលក់បានរាងថោកៗណាស់ៗរកអីទេ

កៈ ហើយបើថាឥឡូវនឹង១០០០$អីនឹងវាមិនទៅម៉េះនោះទេ។

ខៈ នឹងហើយ

កៈ 1000$

ខៈ ១០០០$នឹងវាមិនឹងម៉េះដែរ។

កៈ
ចាស!ហើយទៅដីរបស់អ៊ុំនឹងវាលក់បានប៉ុន្តែដែលគេមានដែលមកលក់មើលកាត់ហាំងឆេងដីដែលឬទេ?

ខៈ
អត់ដឹងអីផងកាលនឹងពេលនឹងគេថាបើដាក់លក់នឹងបានប្រហែលជា២ទៅ៣ម៉ឺនអីនឹងដែល។

កៈ កាលនឹងហោះ?

ខៈ នឹងហើយកាលនឹងវាបាននៅមុខគេហា។

កៈ ចាស!

ខៈហើយទៅណាមួយនឹងដីនឹងវាអត់មាននៅនឹងផ្លូវនឹងចឹងហើយបានជាគេនឹងវាមិនសូវទៅទិញព្រោះវាអត់នៅនឹងផ្លូវ។

កៈ ចាស!ត្រូវហើយដីស្រុកនឹងទាល់តែនៅនឹងផ្លូវតែបើថាដីនឹងវាជាចំការអីនឹងគេបានទិញព្រោះអីគេមានដីនឹងលក្ខណៈរាងបានដីនឹងធំៗចឹងទៅគេបានជួលវិញ។

ខៈ ចាស!គេបានជួល។(មាន់រងាវ)

កៈ ចាស!

ខៈ អានឹងបានវានៅជិតៗគ្នាដែលទេណាបើវានៅឆ្ងាយនៅចុសៗគ្នានឹងគេមិនទៅយកទៀត។

កៈ ចាស!

ខ៖ហើយបើវាមាន១នាក់លក់នឹងហើយមាន១ម្នាក់ទៀតនឹងគេអត់លក់ក៏គេនឹងមិនទៅយកដែល។

ក៖
ចាស!ហើយចុះដីរបស់អ៊ុំនៅកាលពីមុននឹងអ៊ុំបានលក់វានៅក្នុងតំលៃបានប៉ុន្មានដែលទៅអ៊ុំ?

ខ៖
កាលនឹងលក់បាន៥ទៅ៦ម៉ឺនលុយខ្មែរយើងនឹងកាលនឹងដីនឹងមានទំហំតែ៥ទៅ៦ម៉ែត្រយើងនឹងទេ។

ក៖ មិនមែន៥ហិចទេ?

ខ៖ អត់ទេ។

ក៖ ចឹងតែ៥ម៉េត្រទេ?

ខ៖ ចាស!

ក៖ ចាស!

ខ៖
កាលនឹងគេនឹងបានចែកនឹងទៅតាមមនុស្សនឹងកាលនៅជំនាន់នឹងគេបានចែកអោយឪខ្ញុំកាលនឹងគាត់នៅចឹងទៅចឹងហើយកាលនឹងបានជាចែកដីនឹងអោយបានតែ១នឹង១ម៉េត្រនឹង។

ក៖ ចាសអូ!

ខ៖ មានទៅបានស្អីនឹងគេបើកាលនឹងយើងលក់នឹងវានៅរាងថោកនឹងចឹងហើយមិនបានអីទេ។

ក៖ ចឹងបាន៥ម៉ឺន

ខ៖ នឹងបានតែ៥ម៉ឺនលុយខ្មែរយើង។

ក៖ បានតែ៥ម៉ឺងយើងនឹងទៀតនឹងចឹងសោកស្ដាយដែល។

ខ៖ ហាហឺ

ក៖ ហើយចឹងដីនឹងនៅជិតៗនេះឬក៏នៅឯណាដែរ?

ខ៖ ដីនឹងនៅឯក្រោយជិតចំការឯណេ៎។

ក៖ ចាសអូ!ខ្ញុំជិះមកនឹងបានឃើញគេមានដាំចេក។

ខ៖ ចាស!គេបានដាក់ដាំចេក ទ្រព្យ ម្រះ ស្ពៅ ហើយនឹងខ្ញីអីនឹងគេចេះតែដាក់ដាំចឹងទៅ។ ហើយកាលដែលនៅក្នុងជំនាន់របស់ខ្ញុំដែលគេបានដាក់ដាំនឹងគេបានដាក់ដាំតែពោតអីចឹង។

ក៖ ចាស!

ក៖ ចាស!អ៊ុំហើយចឹងអ៊ុំកាលពិជំនាន់មុនមកដលតឡូវយើងនឹងដូចជាអ៊ុំមានបាននឹងជួបកាលលំបាកអ្វីហើយនឹងមានផលលំបាកអ្វីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំណា?

ខ៖ សព្វថ្ងៃនឹងហោ?

ក៖ ចាស!

ខ៖ សព្វថ្ងៃនឹងអត់មានសូវជាបានលំបាកអីនោះទេវាមានជីវៈភាពរស់បានរាងបានសមរម្យ ពេលខ្លះទៅយើងរកបានដោយខ្លួនឯងចឹងទៅវាបានសមរម្យ។

ក៖ ចាស!ហើយកាលពីមុនមកនឹងអ៊ុំមានបានធ្លាប់ជួននឹងកាលលំបាកអីខ្លះដែរឬទេដែលវាធ្វើអោយអ៊ុំមិនអាចនឹងបំភ្លេចបានសោះឡើយណានៅក្នុងជីវិតរបស់អ៊ុំណា?

ខ៖ កាលពីជំនាន់មុននឹងវាចេះតែពិកបាកទៅហើយកាលនឹងដែលបានបែកពីជំនាន់អាពតមកនឹងយើងនឹងមិនមានមុខរបរអីនឹងគេសំរាប់រក។
ហើយកូនៗនឹងគេនៅនឹងជាស្រីៗហើយគេនឹងនៅរៀនដែល។
ហើយចឹងកាលនឹងខ្ញុំនឹងវាលំបាកដែលវាលំបាកនឹងវាលំបាករឿងថាស៊ីចុកនឹង។

ក៖ ចាសចឹងលំបាកតែរឿងស៊ីចុកនឹងតែ១ទេណោសអ៊ុំ?

ខ៖ ចាស!!

ក៖ ហើយអ៊ុំក្រុមគ្រួសារអីនឹងគាត់អត់មានអ្វីទេណ៎អ៊ុំ?

ខ៖ ចាសអត់មានអីនោះទេផងនឹង។

ក៖
ចាសហើយចឹងចុះបទពិសោធន៍របស់អ៊ុំល្អៗរបស់អ៊ុំដែលអ៊ុំបានជួបប្រទះបានកាលពីសម័យមុននឹងមកនឹងតើអ៊ុំមានបានជួបអ្វីខ្លះដែលអ៊ុំបានចង់ចាំនោះទេ?

ខ៖
អត់អត់មានបានសប្បាយចិត្តអីនោះទេកាលនៅជំនាន់នឹងនោះព្រោះអីកាលនឹងមិនមានអ្នកគេសំរាប់នឹងជួយជំហាររកស៊ីអីនឹងចឹងចាស។

ក៖
ចាសហើយចឹងអ៊ុំដូចជាកាលនឹងអ៊ុំអត់ធ្លាប់មានបញ្ហាអីក៏ដូចជាអ៊ុំមានបានសប្បាយចិត្តនៅពេលដែលកូនៗនឹងគាត់រកស៊ីអីបានចឹងហើយគេចេះគិតគូដល់ឪពុកម្តាយ?
ហើយអ៊ុំបានធ្វើអ្វីគេខ្លះ
ដូចជាអ្វី១នឹងដែលល្អចឹងទៅដែលធ្វើអោយអ៊ុំនឹងបានសប្បាយចិត្តនឹងតើអ៊ុំមានដែរឬទេ?

(មានក្មេងៗគេមករកទិញទឹកផឹក។ អ៊ុំបានស្រែកហៅ ស៊ីណាណា)

(មានគេមកដល់ទារយកសូត្រដែលអ៊ុំបានខាលហើយបានសួរទៅអ៊ុំហើយអ៊ុំក៏បានឆ្លើយឡើងថា មើលចាំល្ងាចទៅណា)
ខ៖ ចាសគេបានបង្ខំអីនឹង។

ក៖
ចាសអ៊ុំចឹងអ៊ុំអាចធ្វើវាបណ្តើរទៅអ៊ុំចឹងខ្ញុំអាចនឹងធ្វើការសួរដល់អ៊ុំនៅប៉ុន្មានសំណួរទៀតដែរ។
ចឹងអ៊ុំអាចនឹងធ្វើការងាររបស់អ៊ុំទៅមិនអីនោះទេ។
ហើយសព្វថ្ងៃនឹងអ៊ុំផ្ទះនឹងមានបានកសាងឡើងនឹងនៅក្នុងឆ្នាំណាដែរ?

ខ៖ ផ្ទះនឹងតឹមតែបានធ្វើឡើងនឹងតឹមតែបានប្រហែលជាបានប៉ុន្មានឆ្នាំនឹង បានប៉ុន្មានឆ្នាំក្រោយនឹង។

ក៖ ចឹងកាលដែលអ៊ុំបានធ្វើនឹងបានធ្វើនៅក្នុងម៉ូតអីដែលកាលនឹងអ៊ុំផ្ទះ១នឹង?

ខ៖ កាលនឹងមិនបានដឹងថាគេធ្វើអោយនឹងនៅកនុងម៉ូតអីនោះទេកាលនឹងនោះគឺជាងគេបានធ្វើអោយមកនឹង កាលនឹងជាងនឹងគេចេះតែធ្វើអោយចឹងទៅកាលនឹង។

ក៖ អូ

ខ៖ ហើយមីកូនស្រីនឹងគេចង់បានម៉ូតម៉ាអីនឹងទៅគេក៏បានទៅប្រាប់ជាងធ្វើផ្ទះនឹងទៅ។ហើយគេរកលុយបានទៅគេចេះតែធ្វើទៅ។

ក៖ ចាស!

ខ៖ ហើយខ្ញុំនឹងវារកអីមិនសូវបាននោះទេព្រោះអីខ្ញុំនឹងវាចាស់ណាស់ដែលហើយ។

ក៖ ចាស!ហើយទៅកូនរបស់អ៊ុំនឹងគាត់មានការងារអ្វីគេដែលអ៊ុំ?

ខ៖ កូនរបស់ខ្ញុំនឹងសព្វថ្ងៃនឹងគាត់ក៏ជាអ្នកត្បាញនឹងដូចជាខ្ញុំដែលនឹង។

ក៖ អូ!ចឹងគាត់បានសន្សំលុយនឹងតាមរយៈកាលត្បាញនឹង។

ខ៖ ចាស!គេបានសន្សំលុយនឹងបានតិចៗចឹងទៅ។

ក៖ ចាស!!

ខ៖ (គាត់និយាយប្រាប់ចៅថា ជាប្រយត្ន័ម៉ូតូគេផងរឺយម៉ូតូគេនឹងវាជិះលឿនៗណាស់)

ក៖ ចាស!ហើយចុះកាលផ្ទះរបស់អ៊ុំនៅពីមុនដែលវាមិនទាន់បានផ្ទះចឹងនោះចឹងកាលនឹងអ៊ុំបានធ្វើម៉ូតអីគេដែរ?

ខ៖ កាលមុននឹងផ្ទះឈើតើ។

ក៖ ចាស!!

ខ៖ ចាស!

ក៖ ចាស!ចឹងផ្ទះនឹងបានរុះរើសហើយ?

ខ៖
ចាស!កាលនឹងពេលដែលបានចប់ពីក្នុងសម័យជំនាន់អាពតនឹងមកនឹងវាបានឆេះអស់ទៅកាលនឹងវាឆេះអស់បាត់អាលីងទៅ។

ក៖ អូ!

ខ៖ នោះពេលនឹងកាលនៅក្នុងជំនាន់អាពតនឹងគេបានធ្វើអោយយើង១ខ្ទង១នឹង។

ក៖ ចាស!ចឹងកាលនឹងស្តាយណាស់អ៊ុំណ៎!

ខ៖ ចាស!

ក៖ ចាស!ហើយកាលនឹងបានឆេះចឹងគេបានទំលាក់គ្រាប់បែកមែន?

ខ៖ អត់ទេកាលនឹងគេបានធ្វើការជំលៀសហើយគេបានធ្វើការទំលាក់គ្រាប់ផ្លោង។
គេបានទៅនៅនឹងឯគៀនឃាំងនោះហើយកាលនឹងគេមិនទាន់បាននឹងទំលាក់អស់ណា។

ក៖ ហឺ!ស្តាយមែនទែនណាអ៊ុំហើយចឹងកាលនឹងអ៊ុំនឹងជាដីកេរ្តិ៍?

ខ៖ ចាស!ជាដីកេរ្តិ៍។

ក៖
ចាស!អ៊ុំដោយសារតែការសំភាសន៏របស់អ៊ុំនឹងជាច្រើនទៀតដែលដោយសារតែអ៊ុំអត់ស្វរជាស្រួលនៅក្នុងខ្លួន ចឹង។

ខ៖ ចាស!ហេសៗៗ

កៈ
ចាស!ចឹងហើយតើអ៊ុំនឹងមានពាក្យសំរាប់និយាយជាចុងក្រោយដល់អ្នកដែលគេបានស្តាប់សំលេងរបស់អ៊ុំនៅថ្ងៃនឹងអ៊ុំ?

(សំលេងអ៊ុំគាត់ខាលស្លូត្រ)

កៈ ចាស!អ៊ុំចឹងអ៊ុំមានពាក្យអ្វីដើម្បីនឹងនិយាយដែរឬទេអ៊ុំ?

ខៈ ចាស!មានពាក្យអ្វី!

កៈ ចាស!អ៊ុំមានពាក្យអ្វីដើម្បីនឹងធ្វើការផ្តាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយទៀតណាអ៊ុំ!

ខៈ
មិនដឹងថាមានពាក្យនឹងនិយាយទៅតែគ្រាន់តែថាអោយកូនចៅជំនាន់ក្រោយនឹងអោយវាខំ។ខ្ញុំវាមិនសូវជាអ្នកអីប៉ុននឹងនិយាយទៀតនឹងណា។ហេសៗៗ

កៈ
ចាស!អត់អីទេអ៊ុំ!ហើយអ៊ចង់អោយកូនចៅជំនាន់ក្រោយទៀតនឹងយ៉ាងម៉េចទៀតដែរទៅអ៊ុំ?

ចាស(មានសំលេងផ្គរព្រួសៗៗ)

ខៈ ខ្ញុំវាមិនសូវជាអ្នកដែលចេះនិយាយប៉ុន្មានទេ។

កៈ អត់អីទេអ៊ុំ!

ខៈ (មានគេមានសួរហើយអ៊ុំក៏បានឆ្លើយប្រាប់គេថាសុខណានឹងគេបានមកបង្ខំមកយកស្លូត្រហើយគេបានប្រើអោយគេមកយកនឹងណាហើយខ្ញុំក៏បានប្រាប់គេទៅវិញថាចាំមកយកនៅពេលល្ងាចចឹងទៅ)

(មានសំលេងអ៊ុំខាលស្លូត្រ)

កៈ ចាស!ចឹងអរគុណច្រើនអ៊ុំដែលបានចំណាយពេល។

ខៈ ចាសៗ